# ព្រះរាជក្រម

នស/រកម/០១០២/០០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ាន
## ស្តីពីការតព្វកិច្ចធានារ៉ាប់រងយានយន្ត

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងកួឡាលំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នស-០២.០១.០០០៧

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា** លេខ : ០៨ ច.ល

**គាត ឈន់**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល